ធ ៥-០១-២០១ ប្រក

# ប្រកាស

# ស្តីពី

# ការកំណត់អត្រាការប្រាក់ជាគោលសំរាប់បុនហិរញ្ញប្បទាន

**ប្រការ ១.‐** កំណត់អត្រាការប្រាក់ជាគោល ០,៥០% ក្នុងមួយខែ ឬ ៦%ក្នុងមួយឆ្នាំ សំរាប់អនុវត្តចំពោះការផ្តល់បុនហិរញ្ញប្បទាន ជាប្រាក់រៀលដល់ធនាគារពាណិជ្ជ ដើម្បីឱ្យធនាគារពាណិជ្ជទាំងឡាយអនុវត្តបានល្អនូវការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់របស់ខ្លួន ។

**ប្រការ ២.‐** រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣.‐** អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថាន ធនាគារ និងហិរញ្ញវត្ថុក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តនូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៤.‐** ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០២ នេះតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា : **ជា ចាន់តូ**